MERCEDES COLLEGE



# ទីកន្លែងដែល សិស្សនិស្សិត រីកចម្រើន

កម្មវិធីសិស្សនិស្សិតអន្តរជាតិ

CIS INTERNATIONALLY ACCREDITED SCHOOL

CRICOS Code 00365D

# មហាវិទ្យាល័យមេកសីដេស (Mercedes College)

## អំពីមហាវិទ្យាល័យមេកសីដេស (Mercedes College)

មានទីតាំងស្ថិតនៅទីក្រុង Adelaide ប្រទេសអូស្ត្រាលីភាគខាងត្បូងនោះ មហាវិទ្យាល័យ Mercedes ស្ថិតនៅ Adelaide Hills ជិតឆ្នេរខ្សាច់ពណ៌ស និងបណ្ដាមជ្ឈមណ្ឌលទិញទំនិញនៅមូលដ្ឋាន។ មហាវិទ្យាល័យនេះមានទីតាំងស្ថិតនៅតំបន់ពិសេសកណ្ដាលទីក្រុងភាគខាងត្បូងដែលមានចម្ងាយប្រហែល 7 គីឡូម៉ែត្រជាប់នឹងបណ្ដាកន្លែងដឹកជញ្ជូនដ៏ល្អប្រសើរនៅក្បែរៗនោះ។

ក្នុងនាមជាគ្រឹះស្ថានអប់រំផ្ដល់សញ្ញាប័ត្របរិញ្ញាត្រីអន្តរជាតិ (IB World School) នោះ មហាវិទ្យាល័យ Mercedes មានការប្ដេជ្ញាចិត្តចំពោះការអប់រំដែលផ្ដោតសំខាន់ជាអន្តរជាតិ។ មហាវិទ្យាល័យនេះ ផ្ដល់ជូនការអប់រំពេញលេញជាទូទៅដែលរៀបចំសិស្សឲ្យត្រៀមខ្លួនសម្រាប់ជីវភាពរស់នៅ សេវាកម្ម ភាពជាអ្នកដឹកនាំ និងសមាជិកភាពនៃសហគមន៍ពិភពលោក ហើយនិងជាសមាជិកនៃក្រុមប្រឹក្សាសាលាអន្តរជាតិ (CIS)។

## កម្មវិធីជំនួយការសិក្សាភាសាអង់គ្លេសនៅមហាវិទ្យាល័យ Mercedes

តាមធម្មតា សិស្សដែលមកពីបរទេស ត្រូវឆ្លងកាត់កម្មវិធីភាសាអង់គ្លេសដែលជាផ្នែកមួយនៃការត្រៀមរៀបចំខ្លួនរបស់ពួកគេសម្រាប់ការចូលរៀននៅថ្នាក់សំខាន់ៗនៅមហាវិទ្យាល័យ Mercedes។ នេះអាចមានការផ្ដល់ជូនដោយការរួមបញ្ចូលអ្នកផ្ដល់សេវាកម្មខាងក្នុង និងខាងក្រៅ។

វគ្គសិក្សាភាសាអង់គ្លេសគឺពេញម៉ោង តាមតម្រូវការរបស់ក្រសួងមហាផ្ទៃ (Department of Home Affairs) (អន្តោប្រវេសន៍) សម្រាប់សិស្សដែលមានទិដ្ឋាការសិស្សមកពីប្រទេសមួយចំនួន។ រយៈពេលសិក្សាភាសាអង់គ្លេសក៏អាស្រ័យលើកម្រិតភាសាអង់គ្លេសចាប់ផ្ដើមដំបូងរបស់សិស្ស និងតម្រូវការទាមទារកម្រិតភាសាអង់គ្លេសដែលត្រូវការសម្រាប់ការសិក្សារបស់ពួកគេផងដែរ។

## សញ្ញាប័ត្របរិញ្ញាត្រីអន្តរជាតិ (IB)

សញ្ញាប័ត្រ IB គឺជាសញ្ញាប័ត្រមធ្យមសិក្សាដែលមានការទទួលស្គាល់ជាអន្តរជាតិដែលសិស្សមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ការចូលរៀននៅសាកលវិទ្យាល័យជុំវិញពិភពលោក។ សញ្ញាប័ត្រនេះ ត្រូវបានគេបង្កើតឡើងដើម្បីជួយសម្រួលដល់ការចល័តរបស់សិស្សនិស្សិត និងលើកកម្ពស់ការយល់ដឹងជាអន្តរជាតិ។ កម្មវិធីនេះ ផ្ដល់ជូនវិធីសាស្ត្រដោះស្រាយបញ្ហាដ៏ទូលំទូលាយមួយនៅក្នុងការសិក្សានៅកម្រិតមធ្យមសិក្សារយៈពេលពីរឆ្នាំចុងក្រោយ (ឆ្នាំទី 11 និងទី 12)។

## វិញ្ញាបនប័ត្រអប់រំប្រទេសអូស្ត្រាលីភាគខាងត្បូង (SACE)

វិញ្ញាបនប័ត្រអប់រំប្រទេសអូស្ត្រាលីភាគខាងត្បូង មានការផ្ដល់ជូនសិស្សដែលបានបញ្ចប់កម្រិតមធ្យមសិក្សាជាន់ខ្ពស់របស់ពួកគេដោយជោគជ័យ។ SACE កំណត់លក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ការទទួលសិស្សឱ្យចូលរៀននៅសាកលវិទ្យាល័យអូស្ត្រាលី និងអន្តរជាតិ។ សិស្សសិក្សាមុខវិជ្ជាទូលំទូលាយដែលបើកលទ្ធភាពឱ្យពួកគេបន្តការសិក្សា និងការងារបន្ថែមទៀត។

សិស្សនិស្សិតក្នុងស្រុក និងអន្តរជាតិសម្រេចបានលទ្ធផលនៃការសិក្សាល្អនៅមហាវិទ្យាល័យ Mercedes ក្នុងបរិយាកាសនៃភាពជោគជ័យក្នុងការសិក្សា និងការរីកចម្រើនផ្ទាល់ខ្លួន។ មហាវិទ្យាល័យ Mercedes មានមោទនភាពចំពោះកម្រងព័ត៌មានសិក្សាកម្រិតខ្ពស់របស់ខ្លួន ហើយសិស្សជាង 90 ភាគរយដែលសម្រេចបានការចូលរៀននៅសាកលវិទ្យាល័យកម្រិតទីបីដែលមានជម្រើសមុខវិជ្ជាសិក្សារបស់ពួកគេ។

## ទីកន្លែង និងសម្ភារៈបរិក្ខារសម្រួលដល់ការសិក្សារបស់សិស្ស

មហាវិទ្យាល័យ Mercedes មានអគារអ្នកឯកទេសដែលមានប្រយោជន៍រួមគ្នាជាច្រើន និងកន្លែងសិក្សា ព្រមទាំងទីកន្លែងដែលបានបែងចែកសម្រាប់សិស្សរបស់យើង រួមមានដូចខាងក្រោម៖

- បន្ទប់សិក្សាដ៏ទំនើបដែលមានបច្ចេកវិទ្យា Apple និង កុំព្យូទ័រលើតុ
- បណ្ណាល័យទំនើប និងមជ្ឈមណ្ឌលធនធានព័ត៌មាន
- បន្ទប់សិល្បៈ ការរចនា និងពហុព័ត៌មាន
- ការសម្ដែងនៅរោងមហោស្រពសិល្បៈ (តន្ត្រី ល្ខោន និងភាពយន្ត)
- មន្ទីរពិសោធន៍វិទ្យាសាស្ត្របំពាក់បរិក្ខារយ៉ាងពេញលេញ
- បន្ទប់មេរៀនដែលមានបន្ទប់បង្រៀននៅជាប់គ្នា។
- គ្រឿងបរិក្ខារកីឡា រួមមានកន្លែងលើកទម្ងន់ និងកន្លែងហ្វឹកហាត់ ទីលានលេងក្នុង និងក្រៅអគារ និងទីលានប្រកួត។
- ហាងកាហ្វេសាលាដែលផ្ដល់ជូនចំណីអាហារ និងភេសជ្ជៈមានជម្រើសជាច្រើនសម្រាប់ទិញ
- ហាងនៅមហាវិទ្យាល័យសម្រាប់តម្រូវការឯកសណ្ឋាន សម្ភារៈសិក្សា និងសំបុត្ររថយន្តក្រុង
- ធនធានសិក្សាជាកន្លែងសិក្សាមានលក្ខណៈឯកជនឆ្នាំទី 12 និងអាចចូលប្រើប្រាស់ចេញចូលដោយផ្ទាល់ទៅកាន់អ្នកសម្របសម្រួល/គ្រូបង្រៀនឆ្នាំទី 12
- កន្លែងទទួលទានអាហារក្រៅផ្ទះឆ្នាំទី 12 ដែលអាចចូលប្រើមីក្រូវ៉េវ កំសៀវទឹក និងប្រដាប់កំដៅនំប៉័ង (ប្រដាប់ធ្វើសាំងវិច)
- មជ្ឈមណ្ឌលសិក្សាអន្តរជាតិថ្នាក់ឯកទេស
- កន្លែងអង្គុយលេងទូទៅ និងកន្លែងកំសាន្ត។

## ហេដ្ឋារចនាសម្ព័ន្ធ

មហាវិទ្យាល័យ Mercedes មានក្រុមការងារជាបុគ្គលិកគាំទ្រផ្នែកសិក្សា និងឯកទេសដែលមានការប្ដេជ្ញាចិត្តខ្ពស់។ សិស្សអន្តរជាតិទទួលបានការគាំទ្រដោយអ្នកសម្របសម្រួលផ្នែកសុខុមាលភាពសិស្ស និងកន្លែងស្នាក់នៅ ទីប្រឹក្សាផ្នែកសិក្សា មន្ត្រីផ្នែកផ្ទះឯកជនដែលភ្ញៀវស្នាក់នៅត្រូវបង់ប្រាក់ និងបុគ្គលិកគ្រូបង្រៀនជំនួយការសិក្សា។

ចិត្តវិទូមហាវិទ្យាល័យអាចរកបានដើម្បីជួយ ក្នុងករណីសំខាន់ចាំបាច់។ លើសពីនេះ សិស្សត្រូវទទួលបានការដាក់ជាក្រុមគ្រូនៅផ្ទះដែលមានទំនាក់ទំនងជាមួយសិស្សជារៀងរាល់ថ្ងៃ។

បុគ្គលិក រួមទាំងនាយកមហាវិទ្យាល័យ Mercedes តែងតែទៅលេងប្រទេសកំណើតរបស់សិស្សអន្តរជាតិដែលផ្ដល់ព័ត៌មានផ្ទាល់ខ្លួន និងព័ត៌មានលម្អិតអំពីដំណើរការរីកចម្រើនផ្នែកសិក្សារបស់សិស្សដោយផ្ទាល់ទៅកាន់មាតាបិតា និងក្រុមគ្រួសាររបស់ពួកគេ។

ជាទូទៅ សិស្សនិស្សិតអន្តរជាតិចូលរៀននៅនៅថ្នាក់ទី 10 ឬ 11 ហើយទទួលសញ្ញាប័ត្របរិញ្ញាត្រីអន្តរជាតិ ឬវិញ្ញាបនប័ត្រអប់រំប្រទេសអូស្ត្រាលីភាគខាងត្បូង (SACE)។



# កន្លែងដែល មិត្តភាពរីកចម្រើន

## ទីកន្លែង

ទីក្រុង Adelaide (រាជធានីនៃប្រទេសអូស្ត្រាលីភាគខាងត្បូង) គឺជាទីក្រុងដ៏ស្រស់ស្អាតបំផុតមួយរបស់ពិភពលោក និងមានការរៀបចំប្លង់បានយ៉ាងល្អ។ វាជាទីក្រុងមួយដែលមានប្រជាពលរដ្ឋជាង 1 លាននាក់ដែលមានស្ថិរភាព និងសន្តិភាព។ នាពេលថ្មីៗនេះ ទីក្រុងនេះត្រូវបានបោះឆ្នោតជាប់ជាទីក្រុងដែលអាចរស់នៅបានច្រើនជាងគេលំដាប់ទីបីរបស់ពិភពលោក និងជាទីក្រុងដែលអាចរស់នៅបានច្រើនបំផុតនៅក្នុងប្រទេសអូស្ត្រាលី។

ទីក្រុង Adelaide មានបរិយាកាសសប្បាយរីករាយដែលមានកម្រិតអាកាសធាតុល្មមជាមួយរដូវក្តៅស្ងួត និងត្រជាក់ដល់រដូវរងាមិនសូវខ្លាំងជាមួយនឹងភ្លៀងធ្លាក់ល្មម។ សីតុណ្ហភាពមធ្យមមានចាប់ពី 28°C នៅរដូវក្តៅដល់ 15°C ក្នុងរដូវរងារ។ ដោយមានសួនឧទ្យាន ភ្នំនិងឆ្នេរខ្សាច់ដ៏ស្រស់ស្អាតជាច្រើននោះ ទីក្រុង Adelaide មានរបៀបរស់នៅដ៏រីករាយ ងាយស្រួល និងសម្រាកកាយដែលល្អសម្រាប់ការសិក្សា។

ទីក្រុង Adelaide ក៏មានការចំណាយទាបបំផុតក្នុងការរស់នៅនៃទីក្រុងណាមួយនៅក្នុងប្រទេសអូស្ត្រាលី។ ទីក្រុងនេះ មានពហុវប្បធម៌ និងមានសកម្មភាពវប្បធម៌អន្តរជាតិ និងពិធីបុណ្យជាច្រើន។ ទីក្រុង Adelaide មានហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនសាធារណៈដ៏ល្អប្រសើរ ហើយជាទីក្រុងដែលមានការការពារសន្តិសុខសុវត្ថិភាពកម្រិតខ្ពស់។

## ផ្ទះឯកជនដែលភ្ញៀវស្នាក់នៅត្រូវបង់ប្រាក់

សិស្សអន្តរជាតិនៅមហាវិទ្យាល័យ Mercedes ស្នាក់នៅផ្ទះឯកជនដែលភ្ញៀវស្នាក់នៅត្រូវបង់ប្រាក់ឲ្យម្ចាស់ផ្ទះដែលជាផ្នែកមួយនៃសហគមន៍សាលា និងរៀបចំដោយសាលា។ យើងមានបំណងផ្តល់ជូនសិស្សានុសិស្សទាំងអស់អំពីរបៀបរស់នៅជាគ្រួសារដែលយកចិត្តទុកដាក់ និងចិញ្ចឹមបីបាច់ថែរក្សាដែលជួយពួកគេសម្របខ្លួនទៅនឹងវប្បធម៌អូស្ត្រាលី។ ម្ចាស់ផ្ទះឯកជនដែលភ្ញៀវស្នាក់នៅត្រូវបង់ប្រាក់នៅមហាវិទ្យាល័យ Mercedes ត្រូវតែឆ្លងកាត់ការត្រួតពិនិត្យយ៉ាងដិតដល់ពីអាជ្ញាធររដ្ឋាភិបាល និងផ្នែកនៃការអប់រំ មុនពេលទទួលយកទៅចូលរៀនក្នុងកម្មវិធីផ្ទះឯកជនដែលភ្ញៀវស្នាក់នៅត្រូវបង់ប្រាក់។

សម្រាប់ព័ត៌មានបន្ថែម សូមចូលមើលវិបសាយ mercedes.catholic.edu.au






## ព័ត៌មានលម្អិតអំពីទំនាក់ទំនង

**Leeanne Moriarty**
អ្នកគ្រប់គ្រងទីផ្សារអន្តរជាតិ
ទូរស័ព្ទ៖ +61 8 8372 3227
អ៊ីម៉ែល៖ lmoriarty@mercedes.catholic.edu.au

**Rob O'Toole**
ទីប្រឹក្សាផ្នែកសិក្សា
ទូរស័ព្ទ៖ +61 8 8372 3235
អ៊ីម៉ែល៖ rotoole@mercedes.catholic.edu.au

**Elizabeth Renfrey**
អ្នកសម្របសម្រួលសុខុមាលភាពសិស្ស និងកន្លែងស្នាក់នៅ
ទូរស័ព្ទ៖ +61 8 8433 1323
អ៊ីម៉ែល៖ erenfrey@mercedes.catholic.edu.au

MERCEDES COLLEGE

**មហាវិទ្យាល័យមេកសឺដេស (Mercedes College)**
540 Fullarton Road Springfield South Australia 5062
T +61 8 8372 3200
mercedes@mercedes.catholic.edu.au
mercedes.catholic.edu.au

INTERNATIONALLY ACCREDITED SCHOOL
CRICOS Code 00365D